**សុន្ទរកថារបស់ឯកឧត្តម HORINOUCHI Hidehisa**

**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគារថ្មីនៃ**

**មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង**

**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧**

-សូមគោរព ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស អស់លោក លោកស្រី

ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម ម៉ម ប៊ុនហេង ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគារថ្មីនៃមន្ទីរពេទ្យបង្អែកខេត្តស្វាយរៀងក្នុងថ្ងៃនេះ។

ថ្ងៃនេះខ្ញុំសប្បាយរីករាយណាស់ដែលបានចូលរួមក្នុងពិធីនេះតំណាងឲ្យរដ្ឋាភិបាលជប៉ុន។

ខេត្តស្វាយរៀងជាផ្នែកមួយនៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងដែលរដ្ឋាភិបាលជប៉ុនបានជួយគាំទ្រអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នាពេលអនាគត ត្រូវបានគេរំពឹងថា នឹងមានការរីកចំរើនសេដ្ឋកិច្ចបន្ថែម និងមានការកើនឡើងនូវចំនួនប្រជាជន។ ស្របពេលប្រជាជនមានការកើនឡើង អ្នកជំងឺប្រើប្រាស់មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀងក៏ត្រូវបានគេរំពឹងថានឹងមានការកើនឡើងផងដែរ។

ខ្ញុំសង្ឃឹមថា អគារមន្ទីរពេទ្យ និងសម្ភារៈពេទ្យដែលបានផ្តល់ជូនថ្មីក្រោមគម្រោងនេះអាចប្រើប្រាស់បានយូរអង្វែង ហើយចូលរួមចំណែកក្នុងការពង្រឹងសេវាសុខាភិបាលក្នុងខេត្តស្វាយរៀង និងក្លាយជាមន្ទីរពេទ្យដែលទទួលបានការពេញចិត្តពីប្រជាជនក្នុងខេត្ត។

ជាទីបញ្ចប់ តំណាងឲ្យរដ្ឋាភិបាល និងប្រជាជនជប៉ុន ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះអ្នកទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងនេះ។

សូមអរគុណ!